**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**

លេខ ២៨៦ /២១ ស.ភ.ល

ថ្ងៃពុធ ១៣ កើត ខែអស្សុជ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

ខេត្តកោះកុង ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

## ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០២១

រដ្ឋបាលខេត្តកោះកុង នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១៖អ្នកទទួលការសំណង់ទូទៅ ( សំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២៖អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានរៀបរាប់នៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច០២ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមប្រញាប់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០** វេលាម៉ោង ១៧:០០ នាទី ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត ដោយឥតបង់ថ្លៃ ទំនាក់ទំនង ទូរស័ព្ទ ៖ ០១៥ ៩៦៥ ៦៧៨/០៧១ ៧៨៩ ១១១១ ។

**អភិបាល**

**មិថុនា ភួថង**